00164721

C11/44

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

| | |
|---|---|
| **សំណុំរឿងលេខ៖** | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០១) |
| **បញ្ជូនទៅ៖** | អង្គបុរេជំនុំជម្រះ |
| **កាលបរិច្ឆេទនៃឯកសារ៖** | ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ |
| **ភាគីបញ្ជូន៖** | ការិយាល័យសហព្រះរាជអាជ្ញា |
| **ភាសាដើម៖** | ភាសាអង់គ្លេស |
| **ប្រភេទឯកសារ៖** | ជាសាធារណៈ |

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 25 / 02 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

# ការដាក់ជូនរបស់សហព្រះរាជអាជ្ញា ស្ដីពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្ដោះអាសន្ន

---

**បញ្ជូនដោយ៖**
**ការិ. សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Robert PETIT
លោក យ៉េត ចរិយា
លោក William SMITH
លោក តាន់ សេណារ៉ុង
លោក Anees AHMED

**បញ្ជូនទៅ៖**
**អង្គបុរេជំនុំជម្រះ៖**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ីយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**មេធាវីការពារក្ដីរបស់ នួន ជា៖**
លោក សុន អរុណ
លោក Michel PESTMAN
លោក Victor KOPPE

**មេធាវីការពារក្ដីរបស់ ដើមបណ្ដឹងរដ្ឋប្បវេណី៖**
លោក ហុង គឹមសួន
លោក ឡោ ជុនធី
លោក នី ចាន់ឌី

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22 / 02 / 2008
ម៉ោង (Time/Heure): 14:30 PM
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) គឺជាតុលាការដំបូងគេបង្អស់ និងជាតុលាការព្រហ្មទណ្ឌអន្តរជាតិ ឬដែលធ្វើឲ្យក្លាយទៅជាអន្តរជាតិ បានយល់ព្រមឲ្យមានឋានៈជាភាគីមួយដល់ជនរងគ្រោះពីឧក្រិដ្ឋកម្មផ្សេងៗដែលស្ថិតក្នុងយុត្តាធិការរបស់ខ្លួន[1]។ តុលាការនេះចាត់ទុកពួកគេថាជាដើមបណ្តឹងរដ្ឋប្បវេណី និងគ្រោងទុកជាមុននូវការចូលរួមយ៉ាងសកម្មក្នុងដំណើរការនីតិវិធីរបស់តុលាការនោះ[2] ។ ច្បាប់កម្ពុជា[3] និងច្បាប់នានារបស់យុត្តាធិការថ្នាក់ជាតិដែលស្រដៀងគ្នានេះមួយចំនួន ក៏បានចែងអំពីការចូលរួមយ៉ាងសកម្មរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណាក់ការផ្សេងៗនៃដំណើរការនីតិវិធីព្រហ្មទណ្ឌដែរ[4] ។ ស្រដៀងគ្នានេះដែរ ជនរងគ្រោះត្រូវបានចាត់ទុកថាជា *ភាគីចូលរួម* នៅក្នុងដំណើរការនីតិវិធីនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (“ICC”) ហើយទស្សនៈរបស់ពួកគេត្រូវបានយកទៅពិចារណានៅពេលដែល ទស្សនៈទាំងនោះត្រូវបាន “កំណត់ថាសមស្របហើយ”[5] ។

២. ការអនុវត្តន៍ថ្នាក់ជាតិ និងអន្តរជាតិចែងថា តុលាការអាចធ្វើនិយត្តកម្មលើការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅគ្រប់ដំណាក់ការទាំងអស់នៃដំណើរការនៃនីតិវិធីរបស់ខ្លួនដើម្បី

---

[1] វិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក, វិសោធនកម្ម ១.១ ២០០៨, សន្ទានុក្រម, និយមន័យ *ភាគី* [*បន្ទាប់ពីនេះទៅហៅថា* វិធានផ្ទៃក្នុង] ។

[2] សេចក្តីណែនាំអនុវត្ត ស្តីពីការចូលរួមរបស់ជនរងគ្រោះ, សេចក្តីណែនាំអនុវត្ត ០២/២០០៧, ចុះថ្ងៃទី០៥ តុលា២០០៧ មាត្រា ១.១ [*បន្ទាប់ពីនេះទៅហៅថា* សេចក្តីណែនាំអនុវត្ត] ។

[3] សូមអាន ឧ. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២ ៥ ១៣ ២២ ១៣៤ ១៣៧-៤០ ២៥៣-៤ ២៥៨ ២៦៨ ២៧០ ២៨៦ ២៩៤ ២៩៨ ៣១១-៣ ៣២៤-៨ ៣៣៣-៥ ៣៥៥ ៣៧២ ៣៧៥ ៣៨២ ៣៨៨ ៣៩៣-៦ ៤០២ ៤១៥-៦ ៤១៨ ៤២២ ៤៣៣-៤ ៤៧៥ ៤៨២ ៤៩២ ៥៣៣ ។ល។

[4] សូមមើលជាទូទៅ C Stahn, H Olasolo & K Gibson, ការចូលរួមរបស់ជនរងគ្រោះក្នុងដំណើរការនីតិវិធីបុរេជំនុំជម្រះរបស់ ICC, ចុះថ្ងៃទី០១ មេសា ២០០៦, មនីតិវិធីព្រហ្មទណ្ឌនៃប្រទេស អេស្ពាញ មាត្រា១០១, ទិនានុប្បវត្តិរបស់អង្គការយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ៤ ២ (២១៩) [*បន្ទាប់ពីនេះទៅហៅថា* មាត្រានិយាយពី C Stahn *និងគូកន*] ។ M E I Brienen & E H Hoegen, *ជនរងគ្រោះដោយសារឧក្រិដ្ឋកម្មនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌចំនួន ២២ ប្រព័ន្ធ៖ ការអនុវត្តន៍អនុសាសន៍ (៨៥) ១១ នៃក្រុមប្រឹក្សាអឺរ៉ុប ស្តីពីឋានៈរបស់ជនរងគ្រោះនៅក្នុងទម្រង់ការច្បាប់និងនីតិវិធីព្រហ្មទណ្ឌ៖* បរមាធិប្បាយរបស់សាកលវិទ្យាល័យ Tilburg, Wolf Legal Production, Nijemegen, ឆ្នាំ២០០៧ [*បន្ទាប់ពីនេះទៅហៅថា* បរមាធិប្បាយអំពី Brienen *និងគូកន*] ។

[5] លក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ, មាត្រា ៦៨.៣ [*បន្ទាប់ពីនេះទៅហៅថា* លក្ខន្តិកៈទីក្រុងរ៉ូម] ។

ព្យាយាមរកតុល្យភាពដ៏ត្រឹមត្រូវមួយរវាង ម្ខាងជាអ្នកដំណាងដ៏មានប្រសិទ្ធភាពរបស់ពួកគេ និងម្ខាងទៀតជាការអនុវត្តន៍ឱ្យបានឆាប់រហ័សនូវដំណើរការនៃនីតិវិធី និងសិទ្ធិរបស់ចុងចោទ[6] ។ សហព្រះរាជអាជ្ញា ស្នើឱ្យអង្គបុរេជំនុំជម្រះ ("អ.ប.ជ") ធ្វើការបកស្រាយអំពីវិសាលភាពនៃការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខតុលាការនេះ រួមទាំងនៅក្នុងបណ្តឹងឧទ្ធរណជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្ន ឱ្យមានសេចក្តីដូចៗគ្នា[7] ។

## ២. ប្រវត្តិនៃនីតិវិធី

៣. កាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានស្នើឱ្យគូភាគី និង *មិត្តរបស់តុលាការ* ដាក់ជូននូវឯកសារជាលាយលក្ខ័អក្សរស្តីពីបញ្ហាការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន[8] ។ បន្ទាប់ពីចេញដីកានេះមក មានការជំទាស់មួយពីជនត្រូវចោទ នួន ជា ថានៅក្នុងវិធានផ្ទៃក្នុង ត្រង់វិធាន ២៣ មិនបានចែងពីការចូលរួមបែបនោះទេ ។ នៅក្នុងពេលបើកសវនាការលើបណ្តឹងឧទ្ធរណ៍ កាលពីថ្ងៃទី៨ និងទី៩ ខែកុម្ភៈ ឆ្នាំ២០០៨ ជនត្រូវចោទបានលើកសំអាងថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់សារណាជាលាយលក្ខណ៍អក្សរហើយមិនបានធ្វើការជូនដំណឹងដល់អង្គបុរេជំនុំជម្រះ ឱ្យបានដឹងបំណងចង់ចូលរួមរបស់ខ្លួន ឬតាមពិតដល់ភាគីដទៃៗទៀតទេ ហើយហេតុដូចនេះ អង្គបុរេជំនុំជម្រះមិនត្រូវស្តាប់ចម្លើយរបស់ពួកគេទេ។

៤. សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") ដែលបានឱ្យដើមបណ្តឹងរដ្ឋប្បវេណីចូលរួមនៅក្នុងសវនាការបន្ទាប់ពីមានលិខិតបញ្ជូនរបស់សហព្រះរាជអាជ្ញា("ក.ស.ព") ឬ របស់អង្គភាពជន

---

[6] សូមមើល មាត្រានិយាយពី Stahn *និងគូកន* ទំព័រទី ២-៣ ។

[7] អនុលោមតាមវិធានផ្ទៃក្នុង, វិធាន ២១ ២៣ ។ល។

[8] *ករណីរបស់ នួន ជា,* Public Order on the Filing of Submission on the Issue of Civil Party Participation in Appeals Against Provisional Detention Orders and Invitation to *Amicus Curiae,* សំណុំរឿងព្រហ្មទណ្ឌលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ ០១) ចុះថ្ងៃទី១២ កុម្ភៈ ២០០៨ លេខERN 00162546-00162548, C11/36 [*បន្ទាប់ពីនេះទៅហៅថា* ដីការបស់ អ.ប.ជ] ។

រងគ្រោះ[9] ។ សហចៅក្រមស៊ើបអង្កេតមានការពេញចិត្តថា ជនរងគ្រោះដែលជាអ្នកដាក់ពាក្យសុំបានបំពេញគ្រប់គ្រាន់តាមលក្ខណៈវិនិច្ឆ័យសំរាប់ភាគីដើមបណ្តឹងរដ្ឋប្បវេណីដូចដែលមានចែងនៅក្នុងសេចក្តីណែនាំស្តីពីការចូលរួមរបស់ជនរងគ្រោះ[10] ។ ដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការជូនដំណឹងអំពីរឿងនេះដល់អង្គបុរេជំនុំជម្រះ ដែលអនុញ្ញាតឱ្យពួកគេចូលរួមនៅក្នុងពេលបើកសវនាការលើបណ្តឹងឧទ្ធរណ៍ ដោយបានជូនដំណឹងជាមុនដល់ភាគីផ្សេងៗទៀត[11]។

៥. សហព្រះរាជអាជ្ញា បានភ្ជាប់សារៈសំខាន់ដ៏ធំធេងទៅនឹងបញ្ហាស្តីពីការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ហើយដែលចាប់តាំងពីពេលនេះទៅត្រូវដាក់ឯកសារជាលាយលក្ខណ៍អក្សរទាំងនេះ ដើម្បីជាជំនួយដល់អង្គបុរេជំនុំជម្រះ ក្នុងការកំណត់ឲ្យបានត្រឹមត្រូវលើបញ្ហាទាំងឡាយ ដែលបានលើកឡើងដោយជនត្រូវចោទរូបនេះ ។

## ៣. អំពីច្បាប់

*ច្បាប់របស់ អ.វ.ត.ក*

៦. វិធានផ្ទៃក្នុង ("វិធាន") សម្រាប់តុលាការនេះ គឺជាការបង្រួមបញ្ចូលគ្នានៃនីតិវិធីរបស់កម្ពុជា និងការអនុវត្តន៍និងបទដ្ឋានអន្តរជាតិ ដែលអាចអនុវត្តបានចំពោះតុលាការនេះស្របតាមមាត្រាមួយចំនួនដូចជា មាត្រា២០(ថ្មី) មាត្រា ២៣(ថ្មី) និងមាត្រា៣៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក និងមាត្រា ១២.១ នៃកិច្ចព្រមព្រៀង[12] ។ មាត្រាទាំងនេះចែងថា នៅពេលណាត្រូវបានទទួលយកជាភាគីរដ្ឋប្បវេណីដោយ ស.ច.ស ឬដោយអង្គជំនុំជម្រះហើយនោះ ជនរងគ្រោះនៃបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការនេះ នឹងក្លាយទៅជាគូភាគីនៅចំពោះ

[9] សេចក្តីណែនាំអនុវត្ត មាត្រា ១.២ ។

[10] សេចក្តីណែនាំអនុវត្ត មាត្រា ៣ ។

[11] ដីការបស់ អ.ប.ជ កថាខណ្ឌទី ២ ។

[12] វិធានផ្ទៃក្នុង, បុព្វកថា។

មុខ អ.វ.ត.ក និងមានសិទ្ធិផ្សេងៗដូចដែលបានកំណត់[13] ។ ដូចភាគីម្ខាងទៀតដែរ ពួកគេក៏អាចនឹងត្រូវបានកោះហៅមកចំពោះមុខតុលាការនេះ[14] អាចនឹងត្រូវបានស្តាប់ចម្លើយ[15] អាចនឹងទទួលបានការជូនដំណឹងអំពីដីកាបង្គាប់របស់ខ្លួនទាំងអស់[16] អាចនឹងស្វែងរកសកម្មភាពស៊ើបសួរផ្សេងៗ និងអាចតវ៉ាចំពោះការបដិសេធរបស់ពួកគេ[17] ហើយអាចនឹងទទួលបានការជូនដំណឹងអំពីដីកាដំណោះស្រាយ និងធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនេះ[18] ។ល។

៧. វិធាន ២៣ នៃវិធានផ្ទៃក្នុង បានចងក្រងជាក្រមយ៉ាងទូលំទូលាយនូវច្បាប់ស្តីពីបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយជនរងគ្រោះ ។ យោងតាមវិធាននេះ គោលបំណងនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគឺដើម្បី (ក) ចូលរួមក្នុង*ដំណើរការនីតិវិធីព្រហ្មទណ្ឌ*... ដោយគាំទ្រដល់ការចោទប្រកាន់[19] និង (ខ) អនុញ្ញាតឲ្យជនរងគ្រោះ អាចស្វែងរក... សំណង[20] ។ ច្បាស់ណាស់ថាវិធាន ២៣ ប្រើពាក្យថា *ដំណើរការនីតិវិធីព្រហ្មទណ្ឌ* ដោយគ្មានកំណត់ ហើយគេអាចបកស្រាយបានថាវិធាននេះ គិតទុកជាមុនអំពីការចូលរួមរបស់ជនរងគ្រោះនៅគ្រប់ដំណាក់កាល*ទាំងអស់* នៃដំណើរការនីតិវិធី ។ ជាការបន្ថែមការបកស្រាយរួមគ្នានៃវិធាន ២៣.១.ក និងវិធាន ២៣.១.ខ នាំឲ្យយើងបង្កើតបាននូវសេចក្តីសន្និដ្ឋានតែមួយគត់គឺថា វិធាននេះបានពិចារណាចំពោះការចូលរួមរបស់ភាគីរដ្ឋប្បវេណីមិនត្រឹមតែ ក្នុងគោលបំណងនៃការកំណត់ទៅលើសំណងប៉ុណ្ណោះទេ ប៉ុន្តែតាមពិតគឺទៅលើដំណើរការ នីតិវិធីទាំងមូលតែម្តងនៅចំពោះមុខតុលាការនេះ ។ តុលាការនេះបានបកស្រាយ

---

[13] វិធានផ្ទៃក្នុង, សទ្ទានុក្រម, និយមន័យ *ភាគី* ។ វិធានផ្ទៃក្នុង, វិធាន ២៣.៦.ក ។

[14] វិធានផ្ទៃក្នុង, វិធាន ៥១.១។

[15] វិធានផ្ទៃក្នុង, វិធាន ៥៩.១។

[16] វិធានផ្ទៃក្នុង, វិធាន ៤៦.១។

[17] វិធានផ្ទៃក្នុង, វិធាន ៥៥.១០។

[18] វិធានផ្ទៃក្នុង, វិធាន ៦៧.៥។

[19] វិធានផ្ទៃក្នុង, វិធាន ២៣.១.ក (មានសង្កត់ន័យជា *អក្សរទ្រេត*) ។

[20] វិធានផ្ទៃក្នុង, វិធាន ២៣.១.ខ។

ទៅលើពាក្យ *ដំណើរការនីតិវិធី* ដោយមានរាប់បញ្ចូលទាំងការស៊ើបអង្កេតបឋម ការស៊ើបសួរ ការជំនុំជម្រះក្តី និងការប្តឹងឧទ្ធរណ៍ ផងដែរ[21] ។

៨. ពាក្យ *ដំណើរការនីតិវិធី* មានរាប់បញ្ចូលយ៉ាងច្បាស់នូវបណ្តឹងឧទ្ធរណ៍ដែលបានប្តឹងចំពោះមុខ អ.ប.ជ នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ ។ វិធាន ៧៧.៣ ចែងថា ក្រឡាបញ្ជីរបស់ អ.ប.ជ ត្រូវជូនដំណឹងដល់ភាគីរដ្ឋប្បវេណីនៃបណ្តឹងឧទ្ធរណ៍ទាំងអស់ដែលបានប្តឹងនៅចំពោះមុខអង្គជំនុំជម្រះ ។ ក្រឡាបញ្ជីអាចពិគ្រោះយោបល់លើសំណុំរឿង បញ្ជូនសេចក្តីថ្លែងសំអាង[22] និងអាចបង្ហាញការសង្កេតដោយសង្ខេបនៅចំពោះមុខ អ.ប.ជ[23] ។ ក្រឡាបញ្ជីក៏អាចស្នើសុំ និងស្តាប់នូវបញ្ហាផ្សេងៗទាក់ទងទៅនឹងការបើកសវនាការជាសាធារណៈផងដែរ[24] ។ ជាការបន្ថែម វិធានបានចែងយ៉ាងច្បាស់លាស់អំពីស្ថានភាពដែលភាគីរដ្ឋប្បវេណីអាចប្តឹងទៅ អ.ប.ជ ប្រឆាំងតវ៉ានឹងសេចក្តីសំរេចណាមួយរបស់ ស.ច.ស[25] ។ ស្រដៀងគ្នានេះដែរ វិធានក៏បានចែងយ៉ាងទូលំទូលាយអំពីការចូលរួមរបស់ភាគីរដ្ឋប្បវេណីនៅក្នុងដំណាក់កាលនៃការជំនុំជម្រះក្តី និងការប្តឹងឧទ្ធរណ៍[26] ។

៩. ក្នុងខណៈដែលវិធាននេះបានចែងយ៉ាងទូលំទូលាយអំពីសិទ្ធិរបស់ភាគីរដ្ឋប្បវេណី ដើម្បីចូលរួមនៅក្នុងដំណើរការនីតិវិធី វិធានក៏មានការគិតទុកថា តុលាការអាចនឹងដាក់បញ្ញត្តិអំពីការចូលរួមរបស់ពួកគេដោយការស្នើសុំឲ្យពហុភាគីរដ្ឋប្បវេណីមានស្មាក្តីរួមតែម្នាក់បានហើយ[27] ឬដោយការចាត់តាំងឲ្យមានតែម្នាក់[28] ។ ភាគីរដ្ឋប្បវេណីអាចធ្វើតំណាងជាសមូហភាពដោយ

---

[21] *ករណីរបស់ នួន ជា,* Order Refusing a Request for Annulment, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ចុះថ្ងៃទី២៤ មករា ២០០៨ លេខERN 00159002-00159006, D55/1, កថាខណ្ឌទី ១៣ ។

[22] វិធានផ្ទៃក្នុង, វិធាន ៧៤.៤ ។

[23] វិធានផ្ទៃក្នុង, វិធាន ៧៧.១០ ។

[24] វិធានផ្ទៃក្នុង, វិធាន ៧៧.៦ ។

[25] វិធានផ្ទៃក្នុង, វិធាន ៧៤.៤ ។

[26] សូមមើល ឧ. វិធានផ្ទៃក្នុង, វិធាន ៩១.១, ៩៤.១, ១០៥.១ ។

[27] វិធានផ្ទៃក្នុង, វិធាន ២៣.៨.ក ។

[28] វិធានផ្ទៃក្នុង, វិធាន ២៣.៨.គ ។

ខ្លួនឯងបាន តាមរយៈសមាគមជនរងគ្រោះ[29] ។ ប៉ុន្តែ ដូចដែលការដាក់បញ្ញត្តិដល់ការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីតាមរយៈតំណាងរួមដូច្នេះ តុលាការត្រូវតែធានាឲ្យប្រាកដថា ផលប្រយោជន៍ខុសៗគ្នារបស់ពួកគេពិតជាត្រូវបានធ្វើតំណាង ហើយទំនាស់ខាងផលប្រយោជន៍ពិតជាអាចជៀសវាងបាន[30] ។ ភាគីដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិតវ៉ាជំទាស់នឹងបញ្ញត្តិបែបនេះ[31] ។

*យុត្តាធិការរបស់កម្ពុជា និង យុត្តាធិការជាតិស្រដៀងគ្នាផ្សេងៗទៀត*

១០. ដូចគ្នានឹងវិធាននានារបស់តុលាការនេះដែរ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ក៏អនុញ្ញាតឲ្យជនរងគ្រោះចូលរួមជាភាគីដើមបណ្តឹងរដ្ឋប្បវេណី និងចូលរួមចំណែកនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធីផ្នែកព្រហ្មទណ្ឌផងដែរ[32] ។ ភាគីរដ្ឋប្បវេណីទទួលបានការជូនដំណឹងអំពីសវនាការនៃបណ្តឹងឧទ្ធរណ៍ដោយគ្មានការកំណត់[33] អាចពិគ្រោះយោបល់អំពីសំណុំរឿង និងដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ[34] និងអាចនឹងត្រូវបានបង្គាប់ឲ្យចូលមកបង្ហាញខ្លួនដោយផ្ទាល់ ។ល។[35] នៅខណៈដែលក្រមនេះមិនបាននិយាយអំពីវិសាលភាពនៃការចូលរួមរបស់ភាគីរដ្ឋប្បវេណី នៅក្នុងកំឡុងពេលនៃសវនាការនៃបណ្តឹងឧទ្ធរណ៍ដែលជំទាស់ទៅនឹងការឃុំខ្លួនបណ្តោះអាសន្ន ភស្តុតាងដែលបុគ្គលម្នាក់ៗបានបកស្រាយ អាចឲ្យយើងដឹងថាវត្តមានរបស់ពួកគេគឺមិនមែនជារឿងធម្មតានោះឡើយ ។ ក្រមក៏បានចែងផងដែរឲ្យមានតំណាងស្របច្បាប់ដោយអង្គការសិទ្ធិមនុស្សចំពោះករណីនៃបទល្មើស

[29] វិធានផ្ទៃក្នុង, វិធាន ២៣.៩ ។

[30] វិធានផ្ទៃក្នុង, វិធាន ២៣.៨.ឃ ។

[31] វិធានផ្ទៃក្នុង, វិធាន ២៣.៨.ង ។

[32] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២ ។

[33] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២៥៨ ។

[34] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២៥៩ ។

[35] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២៦០ ។

ជាក់លាក់មួយចំនួន ដោយរួមបញ្ចូលទាំងករណីនៃ ការរើសអើង ទាសកម្ម និងអំពើធ្វើទារុណកម្ម[36] ។

១១. យុត្តាធិការរបស់ទីក្រុងមួយចំនួនក៏ចែងឲ្យមានការចូលរួមរបស់ជនរងគ្រោះផងដែរ នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌនៅមូលដ្ឋាន ទោះបីនៅក្នុងកំរិត[37]ខុសៗគ្នាក៏ដោយ ។ ភាគច្រើននៃយុត្តាធិការទាំងនោះ អនុញ្ញាតឲ្យជនរងគ្រោះចូលរួមនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ឬ *ភាគីរដ្ឋប្បវេណី* ។ ជាឧទាហរណ៍ នៅប្រទេសបារាំង ក្រមនីតិវិធីព្រហ្មទណ្ឌផ្តល់នូវសិទ្ធិចូលរួមជាក់លាក់មួយចំនួនសមល្មមដល់ជនរងគ្រោះ ដូចជាសិទ្ធិសុំផ្តល់ភស្តុតាង និងស្នើសុំឲ្យមានការស៊ើបសួរ[38] ដើម្បីស្វែងរកការធ្វើមោឃៈភាពនៃនីតិវិធី[39] និងជាទូទៅ មានសិទ្ធិយ៉ាងពេញលេញក្នុងការចូលរួមជាភាគី[40] ។

១២. យុត្តាធិការមួយចំនួនតូចដូចជានៅប្រទេសអេស្តូញជាដើម ទទួលស្គាល់សិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមដូចជាព្រះរាជអាជ្ញា ដែលអនុញ្ញាតឲ្យជនរងគ្រោះចូលរួមយ៉ាងពេញលេញជាមួយនឹងសិទ្ធិជាព្រះរាជអាជ្ញា[41] ។ មានយុត្តាធិការដទៃទៀតអនុញ្ញាតឲ្យជនរងគ្រោះធ្វើជាអ្នកនៅក្រោមបង្គាប់ព្រះរាជអាជ្ញា (បុគ្រសម្ព័ន្ធ) ដោយដាក់ជូនភស្តុតាង និងលើកសំណួរ

---

36 ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា១៧, ១៨, ១៩ ។

37 មាត្រានិយាយពី Stahn *និងគូកន* fn ២ ។

38 ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសបារាំង មាត្រា៨១, ៨១-២, ៨២-២ ។

39 ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសបារាំង មាត្រា៨៩-២ ។

40 មាត្រានិយាយពី Stahn *និងគូកន* ទំព័រទី ២ ។ ទោះបីនៅក្នុងមាត្រា១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃប្រទេសបារាំង ភាគីរដ្ឋប្បវេណីមិនអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នដែលចេញដោយចៅក្រមស៊ើបអង្កេតបានឡើយ ក៏ភាគីរដ្ឋប្បវេណីមានសិទ្ធិចូលរួមយ៉ាងសំខាន់បំផុតដូចជា សិទ្ធិឲ្យគេស្តាប់សវនាការពីខ្លួននៅចំពោះមុខ *សភាចៅក្រមស៊ើបអង្កេត (chambre d'‘nstruction) នៅក្រោមមាត្រា២២១-៣ ទាក់ទងទៅនឹងការបន្ថែមពេលវេលានៃការឃុំខ្លួន (សវនាការត្រួតពិនិត្យ - audience de contr‹le)* ។

41 សូមមើល ក្រមនីតិវិធីព្រហ្មទណ្ឌនៃប្រទេស អេស្តូញ មាត្រា១០១, មាត្រានិយាយពី Stahn *និងគូកន* ទំព័រទី ២, សូមមើលជាទូទៅ *សៀវភៅនិយាយពីយុត្តធម៌សំរាប់ជនរងគ្រោះ ស្តីពីការប្រើប្រាស់ និងការអនុវត្តន៍សេចក្តីប្រកាសស្តីពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌ជនរងគ្រោះនៃបទឧក្រិដ្ឋ និងការរំលោភបំពានអំណាច របស់ការិយាល័យនៃអង្គការសហប្រជាជាតិដើម្បីត្រួតពិនិត្យគ្រឿងញៀន និងទប់ស្កាត់បទឧក្រិដ្ឋ* បុរីញូយ៉ក ១៩៩៩ ទំព័រទី ៣៩ ។

ផ្សេងៗទៅលើសាក្សី និង ចុងចោទ ព្រមទាំងបរិយាយអំពីភស្តុតាងនានាដែលបានដាក់ជូននៅក្នុងដំណើរការនីតិវិធី[42] ។

១៣. នៅក្នុងប្រព័ន្ធច្បាប់ដែលជនរងគ្រោះពុំមានសិទ្ធិដូចជាព្រះរាជអាជ្ញាខាងលើនេះ ជនរងគ្រោះនៅមានលទ្ធភាពចូលរួមនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ តាមរយៈការដាក់ជូនសេចក្តីសន្និដ្ឋានពីការវាយតម្លៃពីផលប៉ះពាល់ទៅលើជនរងគ្រោះ ឬសេចក្តីថ្លែងយោបល់ផ្សេងៗរបស់ជនរងគ្រោះ ។ វិធីសាស្ត្រនៃការចូលរួមរបស់ជនរងគ្រោះមួយបែបនេះមានផ្តល់នៅប្រទេសកាណាដា ញូសៀលឡែន និងអៀកឡង់ ព្រមទាំងនៅក្នុងរដ្ឋមួយចំនួនរបស់សហរដ្ឋអាមេរិក និងអូស្ត្រាលី[43] ។

*តុលាការព្រហ្មទណ្ឌអន្តរជាតិ និង យុត្តាធិការអន្តរជាតិផ្សេងៗទៀត*

១៤. អ្នកដែលបានព្រាងលក្ខន្តិកៈទីក្រុងរ៉ូម បានទទួលស្គាល់ជនរងគ្រោះថាជា *អ្នកចូលរួម* នៅក្នុងដំណើរការនីតិវិធីនៅចំពោះមុខ ICC[44] ។ នេះក៏ដោយសារតែមានការសាយភាយកាន់តែទូលំទូលាយនៃការទទួលស្គាល់អំពីសិទ្ធិរបស់ជនរងគ្រោះនៃលទ្ធភាពទទួលបានយុត្តិធម៌ និងការទទួលស្គាល់យ៉ាងពេញលេញថា ផលប្រយោជន៍របស់ពួកគេអាចនឹងខុសៗគ្នាពីផលប្រយោជន៍របស់ព្រះរាជអាជ្ញា និងរបស់រដ្ឋ ជាពិសេសនៅក្នុងដំណើរការនីតិវិធីនៅមុខពេលសវនាការ[45] ។ លក្ខន្តិកៈទីក្រុងរ៉ូមចែងថា ប្រសិនបើផលប្រយោជន៍របស់ជនរងគ្រោះត្រូវបានប៉ះពាល់ ICC ត្រូវពិចារណាពីការព្រួយបារម្ភរបស់ពួកគេទៅតាមដំណាក់សមស្របនៃ

---

[42] មាត្រានិយាយពី Stahn *និងគូកន* ទំព័រទី ២ ។

[43] មាត្រានិយាយពី Stahn *និងគូកន* ទំព័រទី ២ ។

[44] មាត្រានិយាយពី Stahn *និងគូកន* ទំព័រទី ២ ។

[45] សូមមើលគោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំអំពីសិទ្ធិធ្វើបណ្តឹងឧបាស្រ័យ និងសំណងសំរាប់ការរំលោភច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌, ឯកសាររបស់ អ.ស.ប doc. E/CN. 4/2000/62 ចុះថ្ងៃទី១៨ មករា ឆ្នាំ២០០០, ឧបសម្ព័ន្ធ, *សូមមើលផងដែរ* William A Schabas *សេចក្តីណែនាំអំពីតុលាការព្រហ្មទណ្ឌអន្តរជាតិ* សារព័ត៌មាន Cambridge University Press ឆ្នាំ២០០៤ ទំព័រទី ១៧២-១៧៣ ។

ដំណើរការនីតិវិធីធ្វើយ៉ាងណាឲ្យតែស៊ីសង្វាក់គ្នាទៅនឹងសិទ្ធិរបស់ជនជាប់ចោទ និងធានាបាននូវសវនាការមួយដែលត្រឹមត្រូវ និងមិនលំអៀង[46] ។ ដើម្បីធានាបាននូវប្រសិទ្ធិភាពនៃដំណើរការនីតិវិធី ICC អាចស្នើឲ្យជនរងគ្រោះជ្រើសរើសតំណាងរួមស្របច្បាប់មួយរូប[47] ឬក៏ដាក់កំណត់ឲ្យជនរងគ្រោះធ្វើកិច្ចអន្តរាគមន៍របស់ខ្លួនជាការសង្កេតការ ឬជាសេចក្តីសន្និដ្ឋាន ជាលាយលក្ខណ៍អក្សរវិញ[48] ។

១៥. លក្ខន្តិកៈទីក្រុងរ៉ូម និងវិធានស្តីពីនីតិវិធីនិងភស្តុតាងរបស់ ICC បានកំណត់ឲ្យមាននិយាមចំនួនបី សំរាប់ការចូលរួមចំណែករបស់ជនរងគ្រោះ នៅក្នុងដំណើរការនីតិវិធីនៅមុនពេលសវនាការ[49] ។ ជាការបន្ថែម មាត្រា ៦៨.៣ មិនបានចែងអំពីការកំណត់រយៈពេលនៃចូលរួមចំណែករបស់ជនរងគ្រោះក្នុងដំណើរការនីតិវិធីទេ ។ វិធាននេះបានតម្រូវយ៉ាងជាក់លាក់នៅមុនពេលមានការដាក់ ឬធ្វើវិសោធនកម្មទៅលើលក្ខខណ្ឌណាមួយដើម្បីដាក់កំហិតចំពោះសេរីភាពរបស់ចុងចោទណាម្នាក់ អង្គបុរេជំនុំជម្រះរបស់ខ្លួន *ត្រូវ* ស្វែងរកទស្សនៈផ្សេងៗ *លើសពីអ្វីៗទាំងអស់* គឺជាទស្សនៈរបស់ "ជនរងគ្រោះដែលបានធ្វើការប្រាស្រ័យទាក់ទងជាមួយតុលាការចំពោះករណីនោះ និងជាជនដែលអង្គជំនុំជម្រះបានពិចារណាថា អាចនឹងទទួលគ្រោះថ្នាក់បណ្តាលមកពីការដោះលែងចុងចោទណាម្នាក់ ឬបណ្តាលមកពីការដាក់បង្គាប់នូវលក្ខខណ្ឌនៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ"[50] ។

---

[46] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា៦៨(៣) ។

[47] វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់ ICC វិធាន ៩០(២) ។

[48] វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់ ICC វិធាន ៩១(២) ។

[49] ទាំងនេះរួមមានៈ (១) សេចក្តីសន្និដ្ឋាននៃ "ការធ្វើតំណាង" និង "ការសង្កេតការ" នៅក្រោមមាត្រា១៥ (៣) និង មាត្រា១៩, (២) "ការចូលរួម" អនុលោមតាមមាត្រា៥៣ (៣) និងមាត្រា៦១, និង (៣) "ការស្វែងរកទស្សនៈផ្សេងៗរបស់ជនរងគ្រោះ" នៅក្រោមវិធាន៩៣ ។ របបទាំងបីនេះ អនុញ្ញាតឲ្យមានការចូលរួមពាក់ព័ន្ធរបស់ជនរងគ្រោះតាំងពីដំណាក់កាលដំបូងបង្អស់, នៅក្នុងករណីខ្លះគឺនៅមុនការកំណត់អត្តសញ្ញាណជនសង្ស័យ ឬសូម្បីនៅមុនការចាប់ចាប់ផ្តើមការស៊ើបសួរទៅលើ "ស្ថានភាព" ណាមួយក៏មានដែរ។ មាត្រា ១៥(៣) និងវិធាន ៥០(១) វិធាន៥០(៣) វិធាន ៩២(២) និងវិធាន ១០៧(៥) នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់ ICC ក៏អនុញ្ញាតឲ្យមានការចូលរួមពាក់ព័ន្ធរបស់ជនរងគ្រោះផងដែរ នៅចំពោះនៅមុនពេលការចាប់ផ្តើមការស៊ើបសួរណាមួយ ។ ជាការបន្ថែម មាត្រា១៩ អនុញ្ញាតឲ្យមានការចូលរួមពាក់ព័ន្ធរបស់ជនរងគ្រោះនៅពេលណាមាន "ករណីណាមួយ" ត្រូវបានដាក់នៅចំពោះ មុខ ICC ហើយមាត្រា៦១ ផ្តល់ឲ្យមានការចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណាក់កាលនៃការអះអាងអំពីបទចោទ ។

[50] វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់ ICC វិធាន ១១៩(៣) (មានបន្ថែមចំណុចសំខាន់ៗ) ។

១៦. នៅ ICC ជនរងគ្រោះបានចូលរួមចំណែកយ៉ាងសកម្មនៅចំពោះមុខអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គបុរេជំនុំជម្រះសាលាឧទ្ធរណ៍ ចាប់តាំងពីដំណាក់ដំបូងបង្អស់នៃដំណើរការនីតិវិធីមុនពេលសវនាការ ។ នៅក្នុងករណីរបស់ *Lubanga* ដែលជាករណីមុនដំបូងគេបង្អស់របស់ខ្លួន ជនរងគ្រោះបានចូលរួមស្តាប់នៅក្នុង សវនាការបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទទាក់ទងទៅនឹងយុត្តាធិការរបស់តុលាការ[51] ។ នៅក្នុងករណីដូចគ្នានេះ អង្គជំនុំជម្រះសាលាដំបូងបានដាក់ចេញយ៉ាងពិស្តារនូវ "គោលការណ៍ណែនាំទូទៅស្តីពីកិច្ចការទាំងអស់ដែលទាក់ទងទៅនឹងការចូលរួមរបស់ជនរងគ្រោះ ក្នុងដំណើរការនីតិវិធីទាំងមូល" (សេចក្តីសំរេចអំពីសវនាការចំពោះករណីរឿង Lubanga)[52] ។ ជាពិសេស គោលការណ៍នេះពាក់ព័ន្ធទៅនឹងសិទ្ធិរបស់ជនរងគ្រោះនៅក្នុងការចូលរួមស្តាប់សវនាការនានា សន្និសិទអំពីឋានៈ/លក្ខខណ្ឌ ការជំនុំជម្រះក្តី និងការបញ្ជូនសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរជាដើម ។ ក្នុងករណីរបស់ *Lubanga* ដដែលនេះដែរ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃ ICC បានកំណត់ថាជនរងគ្រោះណាម្នាក់ដែលកំពុងស្វែងរកដើម្បីចូលរួមនៅក្នុងបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងការដោះលែងជាបណ្តោះអាសន្ន ត្រូវតែធ្វើឡើងតាមរយៈការដាក់ពាក្យសុំ ដោយរួមមានទាំងសេចក្តីថ្លែងការណ៍អំពីរបៀបថាតើ ផលប្រយោជន៍របស់ខ្លួនទទួលរងការប៉ះពាល់យ៉ាងដូចម្តេចពីបណ្តឹងឧទ្ធរណ៍នេះ និងថាតើគាត់មានមូលហេតុអ្វីខ្លះដែលនាំឱ្យគេគិតថា គាត់គួរតែទទួលបាននូវការស្តាប់សវនាការ ("សេចក្តីសំរេចលើបណ្តឹងឧទ្ធរណ៍របស់ Lubanga")[53] ។ ដោយមានការសំរេចដូច្នេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានអនុញ្ញាតឱ្យ

---

[51] *ស្ថានភាពនៅក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ ក្នុងករណី រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo,* សាលក្រមសំរេចលើបណ្តឹងតុលាការ ស្របតាមមាត្រា១៩(២)(ក) នៃលក្ខន្តិកៈ ចុះថ្ងៃទី០៣ តុលា ២០០៦, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICC, សំណុំរឿងលេខ 01/04-01/06 (OA 4), ចុះថ្ងៃទី១៤ ធ្នូ ២០០៦ កថាខណ្ឌទី ១២, ១៧ ។

[52] *ស្ថានភាពនៅក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោក្នុងករណី រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo,* សេចក្តីសំរេចអំពីការចូលរួមរបស់ជនរងគ្រោះ អង្គជំនុំជម្រះ I នៃ ICC, សំណុំរឿងលេខ 01/04-01/06, ចុះថ្ងៃទី១៨ មករា ២០០៨ ទំព័រទី ២៧ ។

[53] *ស្ថានភាពនៅក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ ក្នុងករណី រដ្ឋអាជ្ញា ទល់នឹង Thomas Lubanga Dyilo,* សាលក្រមសំរេចលើបណ្តឹងឧទ្ធរណ៍របស់ Thomas Lubanga Dyilo ដែលជំទាស់នឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ I, ដែលមានចំណងជើងថា "សេចក្តីសំរេចលើពាក្យសុំដោះលែងជាបណ្តោះអាសន្នរបស់ Thomas Lubanga Dyilo" ("Decision sur la demande de mise en liberte proviso ire de Thomas Lubanga Dyilo"), អង្គជំនុំជម្រះសាលាឧទ្ធរណ៍, សំណុំរឿងលេខ01/04-01/06

ជនរងគ្រោះចូលរួម នៅក្នុងដំណើរការនីតិវិធីនៃបណ្ដឹងឧទ្ធរណ៍ដែលជំទាស់ទៅនឹងការដោះលែងជាបណ្ដោះអាសន្ន[54] ។ ប៉ុន្តែដោយមានមតិណាមួយមិនយល់ស្របនោះ ចៅក្រម សុង (Song) បានមានប្រសាសន៍ថា បើមានការបកស្រាយអត្ថបទច្បាប់ជាមូលដ្ឋានរបស់ ICC រួមជាមួយផងនោះ ពាក្យសុំបែបនេះមិនចាំបាច់សំរាប់ជនរងគ្រោះទេ ។ គាត់បានសំរេចថាការណ៍នេះ "នឹងនាំឲ្យមានជំហ៊ាន នៃនីតិវិធីមិនចាំបាច់ដែលនឹងពន្យឺតដល់ដំណើរការនៃបណ្ដឹងឧទ្ធរណ៍"[55] ។

១៧. ឯកសារសិទ្ធិមនុស្សអន្តរជាតិ ក៏បានផ្ដល់នូវយុទ្ធវិធីយ៉ាងទូលំទូលាយផងដែរ អំពីសិទ្ធិចូលរួមរបស់ជនរងគ្រោះ[56] ។ តុលាការសិទ្ធិមនុស្សអឺរ៉ុប ("ECHR") ក៏បានទទួលស្គាល់ផងដែរអំពីសិទ្ធិដ៏ទូលំទូលាយរបស់ជនរងគ្រោះ និងសាច់ញាតិរបស់គេ ដែលនឹងត្រូវចូលរួមពាក់ព័ន្ធក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ដោយរាប់បញ្ចូលទាំងនៅក្នុងដំណាក់កាលស៊ើបសួរ[57] ។

## ៤. សេចក្ដីសំអាង

---

(OA7), ចុះថ្ងៃទី១៣ កុម្ភៈ ២០០៧ កថាខណ្ឌទី៣(*ចាប់ពីពេលនេះតទៅហៅថា* សេចក្ដីសំរេចលើបណ្ដឹងឧទ្ធរណ៍របស់ Lubanga)។

[54] នៅក្នុងបណ្ដឹងឧទ្ធរណ៍នេះ ជនរងគ្រោះ a/0001/06, a/0002/06, a/0001/06 និង a/0003/06, ត្រូវបានអនុញ្ញាតឲ្យចូលរួមនៅដំណើរការនីតិវិធីតាមសេចក្ដីសំរេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៅថ្ងៃទី១២ ធ្នូ ២០០៦ (ICC-01/04-01/06-769) និងបានផ្ដល់រយៈពេលរហូតដល់ថ្ងៃទី១៥ ធ្នូ ២០០៦ ដើម្បីបង្ហាញទស្សនៈ និងការព្រួយបារម្ភរបស់ខ្លួនទាក់ទងទៅនឹងបណ្ដឹងឧទ្ធរណ៍ដែលបានប្ដឹងដោយជនសង្ស័យ Lubanga អំពីការឃុំខ្លួនរបស់គាត់ ... ។

[55] សេចក្ដីសំរេចលើបណ្ដឹងឧទ្ធរណ៍របស់ Lubanga ។

[56] ឧ. សេចក្ដីប្រកាសស្ដីអំពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌ជនរងគ្រោះ*នៃបទឧក្រិដ្ឋ និងការរំលោភបំពានអំណាច* (GA Res. 40/34 (1985), Sub A.6 (b) (តម្រូវថា ទស្សនៈផ្សេងៗរបស់ជនរងគ្រោះគួរតែត្រូវបានគិតគូរទៅតាមដំណាក់កាលសមស្របនៃដំណើរការនីតិវិធី) ។

[57] *Ogur v. Turkey,* (21594/93), ECHR 30, 92(19990; *Kelly et all v. The United Kingdom,* (30054/96), ECHR 324, 98 (2001) ។ ប៉ុន្តែ នៅក្រោមវិធានស្ដីពីនីតិវិធី និងភស្តុតាងនៃសាលាក្ដីព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតៈយូហ្គោស្លាវី ("ICTY") និង រ្វាំន់ដា ("ICTR") ហើយនិងរបស់តុលាការពិសេសសំរាប់សៀរ៉ាឡេអូន ("SCSL") ជនរងគ្រោះអាចស្វែងរកតែសំណងមួយមុខប៉ុណ្ណោះនៅចំពោះមុខយុត្តាធិការជាតិ បន្ទាប់មានសេចក្ដីសន្និដ្ឋានអំពីដំណើរការនីតិវិធីព្រហ្មទណ្ឌហើយនោះនៅចំពោះមុខសាលាក្ដីអន្តរជាតិ ។ *សូមមើល* វិធានស្ដីពីនីតិវិធីនិងភស្តុតាងរបស់ SCSL វិធាន ១០៥, វិធានស្ដីពីនីតិវិធី និងភស្តុតាងរបស់ ICTY និង ICTR ។ វិធាន ១០៦ ។

១៨. ជាការច្បាស់លាស់ណាស់ថា លិខិត និងស្មារតីនៃឯកសារជាមូលដ្ឋានរបស់តុលាការនេះបាន នាំទៅរកការធ្វើសេចក្ដីសន្និដ្ឋានថា ភាគីដើមបណ្ដឹងរដ្ឋប្បវេណីទាំងឡាយគឺជា *ភាគី* ដែល មានវត្តមាននៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធីព្រហ្មទណ្ឌ ដែលស្ថិតនៅ ចំពោះមុខតុលាការនេះ ។ សហព្រះរាជអាជ្ញា សូមដាក់ជូនថាជាការចាំបាច់ណាស់ដែល ត្រូវរួមបញ្ចូលនូវសវនាការលើបណ្ដឹងឧទ្ធរណ៍ស្ដីពីការឃុំខ្លួនបណ្ដោះអាសន្ននៅចំពោះមុខអង្គ បុរេជំនុំជម្រះផង ។ តាមពិត នេះគឺជាទម្លាប់អនុវត្តន៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ដែលជនរងគ្រោះទាំងឡាយចូលរួម និងត្រូវបានស្ដាប់ចម្លើយ ទោះបីជាតាមបែបណា មួយដែលស្របតាមយុត្តិកម្មនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធី រួមទាំងនៅ ក្នុងពេលបើកសវនាការលើបណ្ដឹងឧទ្ធរណ៍ស្ដីពីការឃុំខ្លួនបណ្ដោះអាសន្នផង[58] ។

១៩. វិធាន ២៣.១.ក បើកឲ្យភាគីដើមបណ្ដឹងរដ្ឋប្បវេណីទាំងឡាយមានសិទ្ធិចូលរួមនៅក្នុងដំណើរ ការនីតិវិធីព្រហ្មទណ្ឌនៅចំពោះមុខ អ.វ.ត.ក "ដោយគាំទ្រដល់ការចោទប្រកាន់" ។ ហេតុដូច នេះ ទោះបីជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីមិនចូលរួមនៅក្នុងសវនាការតទល់[59] ឬមិនមានសិទ្ធិ ក្នុងការប្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នក្ដី[60] ។ គឺពួកគេប្រាកដជា អាចចូលរួមនោះក្នុងសវនាការលើបណ្ដឹងឧទ្ធរណ៍ ស្ដីពីការឃុំខ្លួនបណ្ដោះអាសន្ននៅចំពោះមុខ អង្គបុរេជំនុំជម្រះបានដើម្បីជួយគាំទ្រដល់ការចោទប្រកាន់[61] ។ វិធានដែលមានជាធរមាននៅ ចំពោះមុខ *(ex facie)* តម្រូវឲ្យភាគីដើមបណ្ដឹងរដ្ឋប្បវេណីទាំងឡាយអាចចូលរួមនៅក្នុង

---

[58] វិធានស្ដីពីនីតិវិធីនិងភស្តុតាងរបស់ ICC ត្រង់វិធាន១១៩.៣ ។

[59] វិធាន ៦៣.១ នៃវិធានផ្ទៃក្នុង ។

[60] ជនត្រូវចោទ អាចប្ដឹងឧទ្ធរណ៍ជំទាស់នឹងសេចក្ដីសម្រេចឃុំខ្លួនពន្ធោះអាសន្នបានផ្អែកតាមវិធាន ៦៣.៤ ហើយសហព្រះរាជអាជ្ញា អាចប្ដឹងឧទ្ធរណ៍តវ៉ាចំពោះសេចក្ដីសម្រេចដោះលែងបណ្ដោះអាសន្នបានអនុលោមតាមវិធានផ្ទៃក្នុង ។

[61] តាមពិតគឺមានកាលៈទេសៈជាច្រើននៅក្នុងវិធានផ្ទៃក្នុងនៅពេល ដែលភាគីខ្លះត្រូវបានដកចេញឬគ្រាន់តែពិគ្រោះយោបល់តែប៉ុណ្ណោះ ហើយដែលមិនត្រូវបានអនុញ្ញាតឲ្យចូលរួមដោយពេញលេញនៅក្នុងសវនាការ ។ ឧទាហរណ៍ សូម្បីតែសហព្រះរាជអាជ្ញាក៏ត្រូវបានដក ចេញមិនឲ្យចូលរួមនៅក្នុងពេលចូលបង្ហាញខ្លួនជាលើកដំបូងក្រោមវិធាន ៥៧.១ ដែរឬគេគ្រាន់តែស្នើសុំមតិរបស់សហព្រះរាជអាជ្ញាតែ ប៉ុណ្ណោះផ្អែកតាមវិធាន ៦៤.១ លើបញ្ហាស្ដីពីការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ។ ក៏ប៉ុន្តែនេះគឺមិនទាន់បដិសេធ ឋានៈរបស់ពួកគេជាភាគីនៅឡើយទេ ។

គ្រប់សវនាការលើបណ្ដឹងឧទ្ធរណ៍ទាំងអស់ដែលបើកធ្វើដោយអង្គបុរេជំនុំជម្រះ ក៏ប៉ុន្តែអាចគ្រាន់តែ ផ្តួចផ្តើមគំនិតក្នុងការធ្វើបណ្តឹងឧទ្ធរណ៍តែនៅក្នុងកាលៈទេសៈដោយឡែកមួយចំនួនប៉ុណ្ណោះ ។ ការបកស្រាយផ្ទុយពីនេះ មុខជានឹងកំហិតសិទ្ធរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងការតាំងខ្លួនជា"ភាគីមួយ" នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ដោយផលប្រយោជន៍របស់ខ្លួននៅក្នុង ដំណើរការនីតិវិធីព្រហ្មទណ្ឌមិនមានអ្វីជាតំណាងឲ្យពួកគេ ។ អង្គបុរេជំនុំជម្រះ មុខជានឹងធ្វើ សេចក្តីសម្រេចលើបញ្ហាពាក់ព័ន្ធដោយមិនមានជំនួយពីភាគីមួយក្នុងចំណោមគូភាគីនៅក្នុងសវនាការ ដែលអាចស្តែងចេញនូវភាពជាក់លាក់មួយក្នុងការធ្វើសេចក្តីសម្រេចដោយផ្អែកលើភាគីតែម្ខាងប៉ុណ្ណោះ (*de facto ex parte* decicion) ។ សំខាន់ជាងនេះ ដោយសារអង្គបុរេជំនុំជម្រះអាចពិនិត្យមើលអំពីនីយ័តភាពនៃដំណើរការស៊ើបសួរ នៅក្នុងគ្រប់ដំណាក់កាលនោះ ការច្រានចោលនូវសិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនឲ្យចូលរួមនៅក្នុងសវនាការ អាចនឹងធ្វើឲ្យខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិក្នុងការតាំងខ្លួនជាភាគីមួយរបស់ពួកគេ និងអាចជាការដកហូតចេញនូវជំនួយរបស់ពួកគេដល់អង្គបុរេជំនុំជម្រះនៅលើបញ្ហាដែលសំខាន់ៗ[62] ។

២០. ការទទួលស្គាល់ជនរងគ្រោះទាំងឡាយថាជាភាគី - ហើយថា មិនមែនគ្រាន់តែជាវត្ថុប៉ុណ្ណោះទេ - នៅក្នុងគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី ត្រូវបានណែនាំដោយការពិនិត្យពិចារណាទៅលើផ្នែកច្បាប់ និងផ្នែកគោលនយោបាយដ៏ត្រឹមត្រូវ ។ ជនរងគ្រោះទំនងជាត្រូវបានជូនដំណឹងបានយ៉ាងប្រសើរបំផុតអំពីប្រភេទនិងវិសាលភាពនៃបទល្មើសដែលបានចោទប្រកាន់ ។ ការចូលរួមរបស់ពួកគេនាំយកមកជូនតុលាការជាដំបូងគេនូវការយល់ដឹង និងទស្សនៈវិស័យអំពីមនុស្សនៅក្នុងព្រឹត្តិការណ៍ទាំងនោះ ។ ជាក់ស្តែងគឺពួកគេអាច ផ្តល់ព័ត៌មានដល់តុលាការអំពីបញ្ហានៃការប៉ះទង្គិចយ៉ាងខ្លាំងដល់ជនរងគ្រោះនិងសាក្សីនានា ការរំខានដល់សណ្តាប់ធ្នាប់សាធារណៈ ការប្រើឥទ្ធិពលទៅលើជនរងគ្រោះនិងសាក្សី ការបំផ្លាញស្តុតាង បញ្ហាផ្សេងៗ

[62] សូមអានបទដ្ឋាននៃការពិនិត្យសារឡើងវិញលើបណ្តឹងឧទ្ធរណ៍នៅក្នុងពាក្យសុំឲ្យដោះលែងជាបណ្តោះអាសន្ន ដែលអង្គបុរេជំនុំជម្រះបានដាក់ចេញនៅក្នុងករណីរបស់ ឌុច ។ *ករណីរបស់ កាំង ហ្កេកអ៊ាវ ហៅឌុច* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច លេខស៊ើបសួរ ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០១) ចុះថ្ងៃទី០៣ ធ្នូ ២០០៧ កថាខណ្ឌទី ៨ ។ សូមអានផងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជា ត្រង់មាត្រា២៦១ ។ ការដាក់ជូនរបស់សហព្រះរាជអាជ្ញា ស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ដែលពាក់ព័ន្ធដោយផ្ទាល់ទៅលើការពិនិត្យពិចារណាអំពីការឃុំខ្លួនចុងចោទជាបណ្ដោះអាសន្ន ។ ការចូលរួមរបស់ពួកគេនៅក្នុងដំណាក់កាលបឋមនេះគឺកាន់ តែសំខាន់ថែមទៀត នៅពេលដែលតុលាការធ្វើការកំណត់ដោយពិនិត្យមើលតែមួយភ្លែត (*a prima facie*) លើបញ្ហាជាជាងនៅក្នុងដំណាក់កាលជំនុំជម្រះក្ដី ដែលតុលាការធ្វើការពិនិត្យគ្រប់ភស្តុតាងទាំងអស់ផ្អែកតាមបទដ្ឋាននៃការហួសវិមតិសង្ស័យ[63] ។ ក្នុងកំរិតទូលំទូលាយជាងនេះ ការចូលរួមរបស់ជនរងគ្រោះនាំមកនូវការជឿទុកចិត្តចំពោះដំណើរការនីតិវិធី ដែលដើរតួនាទីយ៉ាងសំខាន់បំផុតក្នុងការអប់រំ និងរួមចំណែកនៅក្នុងការផ្សះផ្សានៅក្នុងសង្គមនៅក្រោយពេលមានជម្លោះដូចជាប្រទេសកម្ពុជានេះ[64] ។

២១. ជាសង្ខេប សហព្រះរាជអាជ្ញា សូមស្នើដាក់ជូនថាវិធានរបស់តុលាការនេះផ្ដល់នូវសេចក្ដីថែងដ៏លំអិតជាងគេបំផុត និងដែលរួមបញ្ចូលផងដែរនូវរបបកំណត់ស្ដីពីការចូលរួមជនរងគ្រោះក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងចំណោមយុត្តាធិការអន្តរជាតិនានា[65] ។ ក៏ប៉ុន្តែដើម្បីផ្ដល់នូវប្រសិទ្ធិភាពឲ្យបានពេញលេញដល់តុលាការនេះ អង្គបុរេជំនុំជម្រះត្រូវតែធ្វើការថ្លឹងថ្លែង ម្ខាងអំពីសិទ្ធិរបស់ជនរងគ្រោះដែលមានចំនួនដ៏ច្រើនដែលត្រូវចូលរួមប្រកបដោយអត្ថន័យនៅក្នុងសវនាការ - ដែលជាសិទ្ធិមួយដែលក្នុងវិធានបានការពារដែលមិនអាចប្រកែកបាន និងដែលត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ស្ដីពីសិទ្ធិមនុស្ស - និងម្ខាងទៀតអំពីសិទ្ធិរបស់ចុងចោទដែលត្រូវទទួលបាននូវការជំនុំជម្រះក្ដីដោយត្រឹមត្រូវយុត្តិធម៌ និងដោយឆាប់រហ័ស ប្រកបដោយភាពសមហេតុផល។

[63] ជាពិសេស នៅក្នុងពេលធ្វើការកំណត់សម្រេចអំពីបញ្ហាផ្សេងៗ តាមវិធាន ៦៣.៣.ក និង ខ។

[64] *សូមអានករណីរឿងរបស់* Stanh *និងគូកន* មាត្រា fn.10 (ដែលពិភាក្សាអំពីការតភ្ជាប់គ្នារវាងការផ្សះផ្សារនិងការចូលរួមរបស់ជនរងគ្រោះដែលបានបង្ហាញឲ្យឃើញច្បាស់ដោយគណៈកម្មការស្វែងរកការពិតនិងការផ្សះផ្សារនៃអាហ្វ្រិកខាងត្បូង ដែលក្នុងនោះចម្លើយត្រូវបានប្រមូលចងក្រងមកពីជនរងគ្រោះដោយសារការរំលោភសិទ្ធិមនុស្សប្រមាណជិតពីរម៉ឺនបួនពាន់នាក់ ។

[65] សហព្រះរាជអាជ្ញា កត់សំគាល់ឃើញថាទោះបីជាមានចែងនៅក្នុងច្បាប់ហើយក្ដី ការណ៍នេះមិនអាចអនុវត្តបាននោះក្នុងប្រទេសកម្ពុជាទេ ។ ក៏ប៉ុន្តែដោយសារការគិតគូរពេញទំហឹងអំពីសិទ្ធិរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីនានាអនុលោមតាមវិធាន និងដើម្បីប្រតិបត្តិតាមទម្លាប់អនុវត្តន៍ និងបទដ្ឋានអន្តរជាតិ-ជាពិសេសតាមទម្លាប់អនុវត្តន៍និងបទដ្ឋានរបស់ ICC-អង្គបុរេជំនុំជម្រះអាចពិនិត្យពិចារណាក្នុងការអនុញ្ញាតឲ្យមានការចូលរួមរបស់ភាគីដមបណ្ដឹងរដ្ឋប្បវេណីឲ្យបានយ៉ាងទូលំទូលាយបំផុតតាមដែលអាចធ្វើទៅបាននៅក្នុងពេលបើកសវនាការរបស់ខ្លួន រួមទាំងនៅក្នុងសវនាការលើបណ្ដឹងឧទ្ធរណ៍ស្ដីពីការឃុំខ្លួនបណ្ដោះអាសន្នផង ។

00164736

C11/44



២២. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា សូមស្នើអង្គបុរេជំនុំជម្រះមេត្តាធ្វើការពិនិត្យពិចារណាលើសេចក្តីស្នើយោបល់ស្តីពីរបបកំណត់ក្នុងការគ្រប់គ្រងលើការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងពេលសវនាការលើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួនបណ្តោះអាសន្នដែលធ្វើនៅចំពោះមុខអង្គបុរេជំនុំជម្រះដែលមានដូចដូចខាងក្រោមនេះ:

១)- គ្រប់ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលបានចូលរួមនៅក្នុងការស៊ើបសួរ ដែលក្នុងនោះដើមបណ្តឹងឧទ្ធរណ៍កំពុងតែត្រូវបានស៊ើបសួរ អាចត្រូវបានចាត់ទុកថា មានសិទ្ធិអាចចូលរួមនៅក្នុងសវនាការឧទ្ធរណ៍ស្តីពីការឃុំខ្លួនបណ្តោះអាសន្នបាន ។

២)- រាល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលមានបំណងចង់ចូលរួមនៅក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ត្រូវដាក់ចម្លើយតបជាលាយលក្ខណអក្សររបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍អនុលោមតាមសេចក្តីណែនាំស្តីពីការដាក់ឯកសារ ។ បន្ទាប់ពីបានទទួលនូវចម្លើយតបជាលាយលក្ខណ៍អក្សរនេះ អង្គជំនុំជម្រះ អាចស្នើសុំឱ្យភាគីមួយ ឬច្រើនធ្វើការជ្រើសរើសតំណាងរួមចំនួនមួយរូប "ជាជនរងគ្រោះ ឬជាមេធាវី ការពារក្តីមួយរូប" ដើម្បីដោះស្រាយរឿងនេះ ។

៣)- ចម្លើយតបជាលាយលក្ខណ៍អក្សរត្រូវតែរៀបរាប់ឱ្យបានច្បាស់លាស់អំពីអង្គហេតុ និងអង្គច្បាប់ស្តីពីបញ្ហាថា ហេតុដូចម្តេចបានជាភាគីដើមបណ្តឹងរដ្ឋប្បវេណីដោយឡែកណាមួយជំទាស់ ឬគាំទ្រចំពោះករណីរឿងរបស់ដើមបណ្តឹងឧទ្ធរណ៍ ។ អាចបើកចំហដល់អង្គបុរេជំនុំជម្រះក្នុងការចាត់ទុកចម្លើយតបជាលាយលក្ខណ៍អក្សររបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីថា គ្រប់គ្រាន់សម្រាប់គោលបំណងនៃសវនាការ ហើយដូចនេះ អង្គបុរេជំនុំជម្រះអាចមិន អនុញ្ញាត្តិឱ្យភាគីនោះធ្វើសេចក្តីថ្លែងដោយផ្ទាល់មាត់តំណាងជួសមុខទេ ទោះបីជាភាគី នោះត្រូវបានអនុញ្ញាតឱ្យចូលទៅអង្គុយនៅក្នុងសាលសវនាការក្តី ។

៤)- អង្គបុរេជំនុំជម្រះ មានឆន្ទានុសិទ្ធិធ្វើការបដិសេធសិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្ប

វេណីណាមួយក្នុងការថ្លែងសំអាងដោយផ្ទាល់មាត់ ទោះបីជាភាគីនោះបានចូលរួម នៅក្នុងការស៊ើបសួរដែលក្នុងនោះ ដើមបណ្តឹងឧទ្ធរណ៍កំពុងតែត្រូវបានស៊ើបសួរក្តី ក៏ប៉ុន្តែមិនមានការដាក់ជូននូវឯកសារពាក់ព័ន្ធណាមួយ ដែលត្រូវបានធ្វើឡើងទាក់ទិន នឹងករណីដោយឡែករបស់ដើមបណ្តឹងឧទ្ធរណ៍នោះទេ ។

៥)- បើសិនជាភាគីដើមបណ្តឹងរដ្ឋប្បវេណីមួយចូលរួមនៅក្នុងការស៊ើបសួរនៅក្រោយរយៈពេលត្រូវដាក់ចម្លើយតបជាលាយលក្ខណ៍អក្សរផុតកំណត់នោះ អង្គបុរេជំនុំជម្រះអាចអនុញ្ញាតឱ្យភាគីនោះស្នើផ្តល់ជូននូវសេចក្តីសំអាងជាលាយលក្ខណ៍អក្សរនៅក្នុងរយៈពេលយ៉ាងយូរ ៤៨ ម៉ោង មុនពេលចាប់ផ្តើមបើកសវនាការលើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ។

៦)- អង្គបុរេជំនុំជម្រះក៏អាចអនុញ្ញាតផងដែរឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីនានា ផ្តល់នូវសេចក្តីសំអាងជាលាយលក្ខណ៍អក្សររបស់ខ្លួនដល់សហព្រះរាជអាជ្ញា រួចហើយស្នើឱ្យសហព្រះរាជអាជ្ញា ធ្វើការដោះស្រាយសេចក្តីសំអាងលើចំណុចពិសេសៗ ដែលលេឡើងនៅក្នុងសេចក្តីសំអាងជាលាយលក្ខណ៍អក្សរទាំងនោះ ។

៧)- ភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំ ឬត្រូវបានផ្តល់ការអនុញ្ញាតនូវវិធានការការពារផ្សេងៗតាមដែលអង្គបុរេជំនុំជម្រះយល់ឃើញថាចាំបាច់[66] ។ និង

៨)- ក្នុងការធ្វើសេចក្តីសម្រេចទៅលើកម្រិតនៃការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេ - ណីនានា ពេលធ្វើសវនាការលើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន អង្គបុរេជំនុំជម្រះ អាចធ្វើការពិគ្រោះយោបល់[67]ជាមួយអង្គភាពជនរងគ្រោះ និងស្នើសុំយោបល់ពីអង្គភាពនេះ តាមការចាំបាច់ ៕

សូមដាក់ជូនដោយសេចក្តីគោរពអំពីយើងខ្ញុំ ។

---

[66] ស្របតាមស្មារតីវិធានផ្ទៃក្នុង គ្រង់វិធាន ២៩ ។

[67] ការស្នើជាយោបល់នេះគួរតែស្របគ្នា ក៏ស្ថិតប៉ុន្តែក្នុងស្មារតីនៃសេចក្តីណែនាំស្តីពីការចូលរួមរបស់ជនរងគ្រោះ ។ សូមអាន សេចក្តីណែនាំអនុវត្ត មាត្រា៣.១០ ។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨

**សហព្រះរាជអាជ្ញា**

| | |
|---|---|
| **លោក យ៉េត ចរិយា** | **លោក** Robert PETIT |
| សហព្រះរាជអាជ្ញារង | សហព្រះរាជអាជ្ញា |